**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

**លេខ** ០៩៦ ទសណ.សជណ

ថ្ងៃអាទិត្យ ១០កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២១

**ជម្រាបជូន**

**ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ ÷** ការបន្តពង្រឹងវិធានការបិទផ្អាកអាជីវកម្ម KTV ក្លឹបកម្សាន្ត (ខារ៉ាអូខេ រង្គសាល ឌីស្កូតែក និងបៀរហ្គាឌិន) និងការត្រួតពិនិត្យឱ្យបានម៉ឺងមាត់ជាប់ជាប្រចាំ។

**យោង ÷** - ប្រកាសលេខ០៤៥ ប្រក ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពី ការធ្វើប្រតិភូកម្មមុខងារផ្តល់សេវាទេសចរណ៍ ទៅឱ្យរដ្ឋបាលរាជធានីខេត្ត

- សេចក្តីជូនដំណឹងលេខ ១២៩ សជណអរហ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ ស្តីពីការបិទ KTV ក្លឹបកម្សាន្ត (ខារ៉ាអូខេ រង្គសាល ឌីស្កូតែក)
- សេចក្តីជូនដំណឹងលេខ ១៣៦ សជណអជឧ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ស្តីពី ស្នើចាត់វិធានការបិទអាជីវកម្ម KTV ក្លឹបកំសាន្ត (ខារ៉ាអូខេ រង្គសាល ឌីស្កូតែក) នៅតាមមូលដ្ឋានអាជីវកម្មដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងទេសចរណ៍ ជាបណ្តោះអាសន្ន
- សេចក្តីជូនដំណឹងលេខ ១៥២ សជណអរហ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ស្តីពីការបិទអាជីវកម្មបៀរហ្គាឌិននៅទូទាំងប្រទេសជាបណ្តោះអាសន្ន
- សេចក្តីជូនដំណឹងលេខ ២៦០ សជណអគឧ ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការអនុវត្តវិធានការនានារបស់រាជរដ្ឋាភិបាល ដើម្បីទប់ទល់ការរីករាលដាលនៃជំងឺកូវីដ១៩ ចំពោះមូលដ្ឋានអាជីវកម្ម KTV ក្លឹបកម្សាន្ត (ខារ៉ាអូខេ រង្គសាល ឌីស្កូតែក និងបៀរហ្គាឌិន)
- សេចក្តីជូនដំណឹងលេខ ៧១០ សជណអគឧ ចុះថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការបន្តបិទសកម្មភាព KTV ក្លឹបកម្សាន្ត (ខារ៉ាអូខេ រង្គសាល ឌីស្កូតែក និងបៀរហ្គាឌិន)
- ស្ថានភាពផ្ទុះឡើងនៃការឆ្លងរីករាលដាលជំងឺកូវីដ១៩ព្រឹត្តិការណ៍សហគមន៍ ២០ ខែកុម្ភៈ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ក្រសួងទេសចរណ៍ សូមជម្រាបជូន **ឯកឧត្តម លោកជំទាវ** ជ្រាបថា ដើម្បីបន្តយ៉ាងសកម្មក្នុងការចូលរួមបង្ការ និងទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩ (COVID-19) ពិសេសព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ មូលដ្ឋានអាជីវកម្ម KTV ក្លឹបកម្សាន្ត (ខារ៉ាអូខេ រង្គសាល ឌីស្កូតែក និងបៀរហ្គាឌិន) ត្រូវបន្តរក្សាការបិទផ្អាកសកម្មភាពអាជីវកម្មឱ្យបានម៉ឺងម៉ាត់ ខ្ជាប់ខ្ជួនជាប្រចាំរហូតដល់មានការសម្រេច និងជូនដំណឹងជាថ្មី។

អគារលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

អាស្រ័យហេតុនេះសូម **ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានីខេត្ត** ត្រូវបន្តជំរុញការបិទ និងត្រួតពិនិត្យមូលដ្ឋានអាជីវកម្ម KTV ក្លឹបកម្សាន្ត (ខារ៉ាអូខេ រង្គសាល ឌីស្កូតែក និងបៀរហ្គាឌិន)ឱ្យបានម៉ឺងម៉ាត់ជាប្រចាំ ដោយអនុវត្តតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាលឱ្យមានប្រសិទ្ធភាព។

សូម **ឯកឧត្តម លោកជំទាវ** ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**ចម្លងជូន ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩ (COVID-19)
- មន្ទីរទេសចរណ៍រាជធានី ខេត្ត "ដើម្បីជ្រាប"
- ឯកសារ-កាលប្បវត្តិ